ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២៥៦២ សហវ.ស

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០២

សូមទូលថ្វាយ_គោរពជូន

សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ
ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង_ស្ថាប័ន
ប្រតិភូរាជរដ្ឋាភិបាល អភិបាល គ្រប់ខេត្ត_ក្រុង

**កម្មវត្ថុ** : ស្តីពីកម្មវិធីនៃកិច្ចប្រតិបត្តិការអធិការកិច្ចហិរញ្ញវត្ថុឆ្នាំ ២០០២

**យោង** : -ព្រះរាជក្រមលេខ ០១នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងក្នុងឆ្នាំ ១៩៩៩ ដែលត្រូវបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រម លេខ ១១នស/៩៤ ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងមានការកែប្រែក្នុងច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងក្នុងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩

- បានឃើញ ច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងក្នុងឆ្នាំ ២០០១ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០
- បានឃើញ ខ្លឹមសារមាត្រា ៧ នៃអនុក្រឹត្យលេខ ០៤ អនក្រ-បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ផ្អែកតាមភារកិច្ចចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២

តបតាមកម្មវត្ថុនិងយោងដូចមានចែងខាងលើ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមទូលថ្វាយ-គោរពជូន សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ និង ប្រតិភូរាជរដ្ឋាភិបាល អភិបាល គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង មេត្តាជ្រាបថា : ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បាន រៀបចំកម្មវិធីនៃកិច្ចប្រតិបត្តិការអធិការកិច្ចហិរញ្ញវត្ថុឆ្នាំ ២០០២ ដែលមានជាអាទិ៍ដូចខាងក្រោម :

**ក_ ការងារអធិការកិច្ចហិរញ្ញវត្ថុជាប្រចាំ :**

ក្នុងគោលបំណងពង្រឹងការងារគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតាមបណ្តាក្រសួង ស្ថាប័ន សហគ្រាស

សាធារណៈ និង បណ្តាខេត្តក្រុងឱ្យមានតម្លាភាព និង ការទទួលខុសត្រូវ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានគំរោង នឹងរៀបចំធ្វើអធិការកិច្ចតាមបណ្តាមុខព្រួញសំខាន់ៗដូចខាងក្រោម :

១- ធ្វើអធិការកិច្ចការគ្រប់គ្រង និង ការប្រើប្រាស់ទុនអចលន៍ " អចលនវត្ថុជួល ម៉ៅការ លក់ បែងចែកនិងការផ្ទេរ " របស់បណ្តាក្រសួង ស្ថាប័នរដ្ឋ សំដៅធានាចំណូលពីការជួល និង លក់អចលនទ្រព្យ បង់ចូលថវិការដ្ឋ និងរក្សាការពារទ្រព្យសម្បត្តិរដ្ឋឱ្យបានគង់វង់ ។

២- ធ្វើអធិការកិច្ចការគ្រប់គ្រង និងការប្រើប្រាស់ទុន ព្រមទាំងការអនុវត្តនីតិវិធីយបង់ចូលថវិការដ្ឋរបស់បណ្តាសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ ក្រុមហ៊ុនរដ្ឋ និងក្រុមហ៊ុនចំរុះរដ្ឋឯកជន ។

៣- ធ្វើអធិការកិច្ចការអនុវត្តន៍គំរោងចំណូល-ចំណាយថវិកាចំពោះបណ្តាអង្គភាពរដ្ឋបាលកណ្តាលនៃក្រសួងស្ថាប័ន និង មន្ទីររដ្ឋបាលខេត្ត-ក្រុង ។

៤- ធ្វើអធិការកិច្ចរាល់ការចំណាយវិនិយោគរបស់រដ្ឋ និង លទ្ធកម្មសាធារណៈ ។

៥- ធ្វើអធិការកិច្ចការប្រមូលពន្ធរបស់នាយកដ្ឋានពន្ធដារ ទីចាត់ការគយ និងរដ្ឋាករ ព្រមទាំងបណ្តាសាខា-ស្នាក់ការ ( ពន្ធដារ និង គយរដ្ឋាករ ) តាមបណ្តាខេត្ត-ក្រុង ។

៦- ធ្វើអធិការកិច្ចការគ្រប់គ្រងចំណូល និងការបែងចែកថវិការបស់ធនាគារជាតិ និងធនាគារខេត្ត-ក្រុង ។

៧- ធ្វើអធិការកិច្ចការគ្រប់គ្រងចំណូលពុំមែនសារពើពន្ធរបស់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតាមបណ្តាខេត្ត-ក្រុង ។

៨- ធ្វើការត្រួតពិនិត្យសារឡើងវិញនៅតាមបណ្តាអង្គភាពដែលបានធ្វើអធិការកិច្ចរួចហើយដើម្បីក្តាប់បាននូវលទ្ធផលនៃការអនុវត្តន៍កែលំអតាមសំណូមពររបស់អធិការកិច្ចដែលបានលើកឡើង ។

៩- ធ្វើអធិការកិច្ច ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ( CDC ) និង ក្រុមហ៊ុនវិនិយោគឯកជនព្រមទាំងអង្គការក្រៅរដ្ឋាភិបាល (NGO ) ដែលមិនរកប្រាក់ចំណេញនានា និង បានទទួលផលប្រយោជន៍ដោយផ្ទាល់ ឬ ដោយប្រយោលពីរាជរដ្ឋាភិបាល ។

១០- ធ្វើអធិការកិច្ចលើអង្គភាពប្រតិបត្តិគំរោង( PIU ) នៅតាមបណ្តាក្រសួង ស្ថាប័ន ខេត្ត-ក្រុង ដែលបានទទួលការផ្តល់ជំនួយ និង កម្ចីឥណទានពីអង្គការអន្តរជាតិផ្សេងៗ ដោយផ្តោតជាសំខាន់លើការប្រើប្រាស់ថវិកាបដិភាគរបស់រាជរដ្ឋាភិបាល ។

១១- ធ្វើអធិការកិច្ចលើអង្គភាពប្រតិបត្តិគំរោងកម្មវិធីសកម្មភាពជាអាទិភាព (PAP ) ដែលបានទទួលការគ្រប់គ្រងថវិកាពីអង្គភាពយុទ្ធសាស្ត្រ និងគ្រប់គ្រងការអនុវត្តន៍ថវិកា (BSEC ) ។

១២- ធ្វើអធិការកិច្ចលើក្រុមហ៊ុនធានារ៉ាប់រងជាតិ និង ស្ថាប័នហិរញ្ញវត្ថុ ។

១៣- ធ្វើអធិការកិច្ចដោះស្រាយរាល់ពាក្យបណ្តឹងតវ៉ា បរិហារ ដែលពាក់ព័ន្ធនឹងផ្នែកហិរញ្ញវត្ថុ ។

១៤- ធ្វើអធិការកិច្ចលើការគ្រប់គ្រងរូបិយវត្ថុ និង រូបិយប័ណ្ណរបស់ធនាគារជាតិក្នុងករណីចូលរួមជាមួយធរណេកម្មការពិសេសរបស់រាជរដ្ឋាភិបាល ។

ខ. ត្រៀមលក្ខណៈធ្វើអធិការកិច្ចចៃដន្យ :

- តាមសំណូមពររបស់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង និងសហគ្រាសសាធារណៈ
- តាមតម្រូវការជាក់ស្តែងនៃការងារ
- តាមការណែនាំរបស់រាជរដ្ឋាភិបាល
- សហការជាមួយអាជ្ញាធរសវនកម្មជាតិ

សេចក្តីដូចបានទូលថ្វាយ និង ជំរាបជូនក្នុងកម្មវិធីនៃកិច្ចប្រតិបត្តិការអធិការកិច្ចហិរញ្ញវត្ថុខាងលើ សូមសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ គ្រប់ក្រសួង ស្ថាប័ន និងប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង មេត្តាជ្រាបជាពត៌មាន និងមេត្តាចូលរួមសហការ ឱ្យបានសំរេចជោគជ័យ ។

សូមសម្តេច ព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ មេត្តាទទួលនូវការរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

ទេសរដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ឯកសារ-កាលប្បវត្តិ